## គោលការណ៍បង្គុំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវរួមមាន:

| | | |
|---|---|---|
| ១- ប្រើប្រាស់ពូជសុទ្ធ | ជ្រើសរើសឬត់ចត់ | មានគុណភាពខ្ពស់ |
| ២- សាបលើថ្នាលគោក | ដីមានមមោក | សំណាបថ្លោសល្អ |
| ៣- ភ្ជួរឲ្យប្រសើរ | កៀរដីឲ្យស្មើ | រាស់ឲ្យបានម៉ដ្ឋ |
| ៤- ប្រើសំណាបខ្ចី | ដកដោយថ្នមដៃ | មិនបាក់របួស |
| ៥- ស្ទូងព្រោះជាជួរ | ចន្លោះសមគួរ | តាមប្រភេទដី |
| ៦- គ្រប់គ្រងជីជាតិ | យកជីធម្មជាតិ | ជាមូលដ្ឋានគ្រឹះ |
| ៧- ផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ | តាមរូវបន្ទាន់ | តាមដំណាក់កាល |
| ៨- វិធានចម្រុះ | អនុវត្តឥតខ្ចោះ | ការពារដំណាំ |
| ៩- ប្រមូលផលស្រូវដែលទុំ | សម្ងួតសមរម្យ | ទុកដាក់ត្រឹមត្រូវ ។ |

## តើកសិករនឹងទទួលបានផលប្រយោជន៍អ្វីខ្លះ ពីការអនុវត្តតាមបង្គុំបច្ចេកទេស ប្រពលវប្បកម្មដំណាំស្រូវ

- កាត់បន្ថយបរិមាណគ្រាប់ពូជ ធ្វើឲ្យចំណេញថវិកា។
- បានជ្រើសរើស និងប្រើប្រាស់គ្រាប់ពូជដែលមានគុណភាពល្អ។
- ដំណាំស្រូវលូតលាស់ល្អតាមសក្តានុពលរបស់វា។
- កាត់បន្ថយការបាត់បង់ជីជាតិ និងកែលំអគុណភាពដី។
- កាត់បន្ថយចំណាយមិនចាំបាច់មួយចំនួនពីការទិញជីគីមីនិងថ្នាំកសិកម្ម។
- ធ្វើឲ្យបរិស្ថានដំណាំស្រូវល្អប្រសើរ និងមាននិរន្តរភាពផលិតកម្ម។
- កសិករកាន់តែស្រឡាញ់ស្រែ និងចុះពិនិត្យស្រែជាប្រចាំ។
- ទិន្នផលដំណាំស្រូវកើនឡើងពី ៣០-៥០% និងទទួលបានប្រាក់ចំណេញកាន់តែច្រើន បើធៀបនឹងទំលាប់កសិករ។
- កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់បានមួយកំរិតផងដែរ។

### ១. ប្រើប្រាស់គ្រាប់ពូជគុណភាពល្អ

( ប្រើប្រាស់ពូជសុទ្ធ ជ្រើសរើសឬត់ចត់ មានគុណភាពខ្ពស់)

- ប្រើពូជដែលមានដំណុះខ្ពស់ចាប់ពី ៨៥% ឡើងទៅ ។
- ប្រើប្រាស់ពូជសុទ្ធ មិនលាយពូជផ្សេង គ្រាប់ស្មៅ និងកើតជំងឺ។
- ប្រើប្រាស់ពូជដែលបានសម្រិតសម្រាំង ឬពូជមានប្រភពច្បាស់លាស់។
- ប្រើប្រាស់ពូជដែលផ្តល់ទិន្នផលខ្ពស់ ធន់នឹងសត្វ និងជំងឺទៅតាមរដូវកាល និងតម្រូវការទីផ្សារ ។



គ្រាប់ពូជមានគុណភាពល្អ និងមានដំណុះខ្ពស់

### ២. ការសាបសំណាប

(សាបលើថ្នាលគោក ដីមានមមោក សំណាបថ្លោសល្អ)

ដើម្បីទទួលបានសំណាបថ្លោស និងសុខភាពល្អសម្រាប់យកទៅស្ទូង កសិករគួរអនុវត្តដូចខាងក្រោម:

- រៀបចំថ្នាលសំណាបឲ្យបានល្អ ដោយភ្ជួររាស់ដីឲ្យបានយ៉ាងតិច ២ដង សំអាតស្មៅ និងពង្រាបដីឲ្យបានរាបស្មើ។
- ប្រើជីធម្មជាតិ ជាពិសេសជីកំប៉ុស្តដែលពុកផុយល្អក្នុងបរិមាណ ២០០ គ.ក្រ ក្នុងដី ១០០ម$^{២}$ និងជ្រុំលាយលើថ្នាលឲ្យបានសព្វល្អ។
- ថ្នាលសំណាបអាចលើកដូចជារងស្ពៃ ដែលមានទទឹងពី ១,៥-២ម និងបណ្តោយអាស្រ័យលើស្ថានភាពដី។ សម្រាប់ស្ទូងលើដី ១ហត ត្រូវការថ្នាលទំហំពី ១០០-១៥០ម$^{២}$ប្រើគ្រាប់ពូជពី១០-១៥ គ.ក្រ។
- បណ្តុះគ្រាប់ជាមុន ដោយត្រាំគ្រាប់ពូជរយៈពេល ១២ ម៉ោង និងផ្អាប់រយៈពេល ២៤ ម៉ោង (គ្របចំបើងពីលើ និងផ្សើមទឹកឲ្យបានញឹកញាប់)។
- បន្ទាប់ពីសាបរួច ត្រូវស្រោចទឹកឲ្យបានជោគ និងស្រោចជាប្រចាំ (២-៣ដង/ថ្ងៃ)។
- ប្រើជីអ៊ុយរ៉េ លាយទឹកស្រោចកំរិត ០.៥គ.ក្រ សំរាប់ផ្ទៃដី ១០០ម$^{២}$ បន្ថែម ដើម្បីឲ្យសំណាបថ្លោសល្អ ប្រសិនបើពិនិត្យឃើញសំណាបលូតលាស់មិនសូវល្អ ។ ត្រូវពិនិត្យ និងកំចាត់សត្វស៊ីបំផ្លាញដំណាំជាពិសេសពពួកទ្រីប និងមមាច។



ការរៀបចំថ្នាលសំណាបគោក

### ៣. ការរៀបចំដីស្ទូង

(ភ្ជួរឲ្យប្រសើរ កៀរដីឲ្យស្មើ រាស់ឲ្យបានម៉ដ្ឋ)

- ត្រូវភ្ជួរឲ្យបានសព្វល្អ ហាលដីឲ្យបាន ១-២ សប្តាហ៍ (ភ្ជួរលប់ស្មៅគល់ជញ្ជ្រាំង និងជីកំប៉ុស្ត)។
- ភ្ជួរឲ្យបានជំរៅពី ១៥-២០ ស.ម (១.៥-២ តឹក) ចំនួន ២-៣ដង រាស់ឲ្យបាន ១ដង និងកៀរពង្រាបឲ្យបានស្មើល្អមុនពេលស្ទូង។
- ប្រើរនាស់ដែលមានធ្មេញកោងឡើងលើ ដើម្បីរាស់ពន្លិចស្មៅចូលក្នុងដី។
- គួរធ្វើចង្អូរសម្រាប់បង្ហូរទឹកចេញចូល។



ការរៀបចំដីឲ្យបានស្មើល្អ

### ៤. ការប្រើប្រាស់សំណាប

(ប្រើសំណាបខ្ចី ដកដោយថ្នមដៃ មិនបាក់របួស)

- ប្រើប្រាស់សំណាបខ្ចី (សម្រាប់ស្រូវស្រាលគួរស្ទូងសំណាបអាយុតិចជាង ២០ថ្ងៃ ហើយស្រូវកណ្តាល និងស្រូវធ្ងន់ អាយុតិចជាង ៣០ ថ្ងៃ)។
- ដកសំណាបថ្នមៗ ឬប្រើឧបករណ៍ជាជំនួយ (ចបចក់ ឬកូនប៉ែល)។
- ដកសំណាបដាក់ក្នុងចានដែក កញ្ជើ ឬល្អី (ចៀសវាងចងរឹតដើមសំណាប)។
- ជ្រើសយកតែសំណាបថ្លោសទៅស្ទូង។
- យកសំណាបទៅស្ទូងភ្លាមបន្ទាប់ពីដករួច។

### ៥. ការស្ទូង

(ស្ទូងរាក់ចាប់ស្តើង ជាជួរល្អឡើង មានខ្នាតត្រឹមត្រូវ)

- គួរស្ទូងជាជួរ ដើម្បីឲ្យមានខ្យល់ និងពន្លឺថ្ងៃចូលល្អ។
- គួរស្ទូង ១ ដើមក្នុង ១ គុម្ព បើសំណាបថ្លោស ដើមខ្ចី និងស្រែមានទឹកតិច ឬស្ទូង ២-៣ដើម ចំពោះសំណាបមិនសូវថ្លោស។
- ត្រូវស្ទូងរាក់ៗ (ជំរៅពី ១-២ ស.ម) និងមិនឲ្យបត់ឫសដូចផ្លែសន្ទូច។ ត្រូវលៃចន្លោះគុម្ពសមស្របអាស្រ័យនឹងប្រភេទដី និងកំរិតជីជាតិ។ដីមិនសូវសំបូរជីជាតិស្ទូងចន្លោះ២០ស.មx២០ស.ម ដីមានជីជាតិមធ្យម ស្ទូង ២៥ ស.ម x ២៥ ស.ម និងដីសំបូរជីជាតិ ស្ទូង ៣០ សម x ៣០ ស.ម ។



ការស្ទូងជាជួរ

## ៦. ការគ្រប់គ្រងជីជាតិដី

(គ្រប់គ្រងជីជាតិ យកជីធម្មជាតិ ជាមូលដ្ឋានគ្រឹះ)

- ត្រូវប្រើប្រាស់ជីធម្មជាតិជាមូលដ្ឋាន ៣–៥ តោន/ហ.ត និងប្រើប្រាស់ជីគីមីបន្ថែម បើពិនិត្យឃើញ ដំណាំស្រូវខ្វះជីជាតិ។
- ប្រើជី DAP ទ្រាប់បាត ឬ បាចបំប៉ន ១៥ ថ្ងៃក្រោយស្ទូងនិងប្រើជីអ៊ុយរ៉េបំប៉ន១៥ថ្ងៃ ក្រោយស្ទូង និងនៅតំណាក់កាលកកើតកួរ
- ព្យាយាមភ្ជួរលុបគល់ជញ្រ្ជាំង និងកាកសំណល់រុក្ខជាតិផ្សេងៗកប់ទៅក្នុងដី ដោយជៀសវាងការដុតចោលបន្ទាប់ពីប្រមូលផលរួច។
- ព្យាយាមដាំដុះដំណាំផ្សេងៗមុនពេលដាំដុះស្រូវ និងក្រោយពេលច្រូតកាត់រួច ជាពិសេសដំណាំអំបូរសណ្តែក ដើម្បីបង្កើនប្រាក់ចំណូល និងកែគុណភាពដី។



ការសន្សំជីកំប៉ុស្ត

## ៧. ការគ្រប់គ្រងទឹក

(ផ្តល់ទឹកគ្រប់គ្រាន់ តម្រូវបន្ទាន់ តាមដំណាក់កាល)

- គួររក្សាទឹកក្នុងស្រែក្នុងកំរិត ២–៣ ស.ម នៅពេលស្ទូង។
- គួររក្សាទឹកក្នុងស្រែក្នុងកំពស់ប្រមាណ ៥ ស.ម ក្រោយពេលស្ទូង។
- នៅវគ្គលូតលាស់ គួរទុកស្រែឲ្យស្ងួតទឹកក្នុងរយៈពេលពី ២–៣ថ្ងៃមុននឹងបញ្ចូលទឹកជាថ្មីឲ្យបានយ៉ាងតិច ១ លើក។
- គួរជីកស្រះនៅជ្រុងណាមួយនៃស្រែ ដើម្បីផ្ទុកទឹកសម្រាប់ស្រោចស្រពនៅពេលជួបគ្រោះរាំងស្ងួតរយៈពេលខ្លី។
- ជៀសវាងទុកស្រែឲ្យស្ងួតរយៈពេលយូរពេក នាំឲ្យស្មៅដុះ និងធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់របស់ដំណាំស្រូវ។
- ថែទាំប្រព័ន្ធភ្លឺឲ្យបានរឹងមាំ និងបិទរន្ធក្តាមតាមភ្លឺស្រែឲ្យបានល្អ។

## ៨. ការគ្រប់គ្រងសមាសភាពចង្រៃ

(វិធានចម្រុះ អនុវត្តឥតខ្ចោះ ការពារដំណាំ)

ការគ្រប់គ្រងស្មៅចង្រៃ



ការធ្វើស្មៅដោយប្រើប្រាស់ឧបករណ៍បំផុសដី

- ត្រូវភ្ជួរដាស់ដី និងហាលឲ្យបានយ៉ាងតិច ១៥ ថ្ងៃ មុននឹងភ្ជួររាស់សម្រាប់ស្ទូង។
- ត្រូវកៀរពង្រាបដីស្រែឲ្យបានស្មើល្អ និងបញ្ចូលទឹកក្នុងស្រែឲ្យបានជាប្រចាំ ។
- ធ្វើស្មៅបំផុសដីនៅក្នុងវគ្គលូតលាស់ឲ្យបាន១–២ ដង តាមស្ថានភាពស្មៅដោយដៃ ឬឧបករណ៍ធ្វើស្មៅ។

ការគ្រប់គ្រងសត្វចង្រៃបំផ្លាញដំណាំ

- ត្រូវត្រួតពិនិត្យទាំងវត្តមានសត្វបំផ្លាញដំណាំនិងសត្វមានប្រយោជន៍ក្នុងស្រែឲ្យបានជាប្រចាំ។
- ប្រើប្រាស់វិធានការចម្រុះការពារដំណាំដូចជា វិធានការមេកានិចដាំដុះ ជីវសាស្ត្រ ថ្នាំផ្សំពីរុក្ខជាតិ និងប្រើប្រាស់ថ្នាំកសិកម្ម ដែលជាវិធានការចុងក្រោយក្នុងករណីមានការផ្ទុះរាលដាល។



ការគ្រប់គ្រងជម្ងឺ

- ត្រូវប្រើប្រាស់ពូជធន់នឹងជម្ងឺ និងពូជពុំមានកើតជម្ងឺ
- ត្រូវផ្តល់សារធាតុចិញ្ចឹមគ្រប់គ្រាន់និងមានតុល្យភាព
- ត្រូវបំបាត់ជំរកជម្ងឺ តាមរយៈធ្វើអនាម័យស្រែ
- ត្រូវកំចាត់ភ្នាក់ងារចំលងជម្ងឺ
- ត្រូវប្រើប្រាស់ថ្នាំសំលាប់ជម្ងឺ ក្នុងករណីមានផ្ទុះរាលដាលខ្លាំង។

## ៩. ការប្រមូលផល និងការទុកដាក់

(ច្រូតស្រូវដែលទុំ សម្ងួតសមរម្យ ទុកដាក់ត្រឹមត្រូវ)

- ការប្រមូលផលគួរធ្វើនៅពេលស្រូវទុំពី៨០–៨៥%ពោលគឺនៅក្នុងផ្ទៃស្រែមានពណ៌លឿងទុំ។
- ត្រូវបោកបែន និងហាលសម្ងួតឲ្យបានល្អ ដោយរក្សាសំណើមគ្រាប់ពី ១២–១៣ %។
- ស្រូវដែលសម្រិតសម្រាំងធ្វើពូជ ត្រូវទុកឲ្យទុំល្អ ហើយត្រូវច្រូតបោកបែន និងរក្សាទុកដាច់ដោយឡែកពីស្រូវសំរាប់ធ្វើស្បៀង ឬលក់ ។
- ត្រូវដាក់ផ្លាកសំគាល់លើបាវស្រូវពូជទៅតាមប្រភេទពូជនីមួយៗ។



ការទុកដាក់ផលស្រូវក្រោយពេលច្រូតកាត់

# បច្ចេកទេស
# ប្រពលវប្បកម្មដំណាំស្រូវ



រៀបចំដោយ

នាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម

សហការជាមួយអង្គការ Oxfam

ខែ មេសា ឆ្នាំ ២០១១

អាសយដ្ឋានទំនាក់ទំនង : ដីឡូត៍លេខ ៥៦ ផ្លូវលេខ ៦៥៦ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ : ០២៣ ៩៩៦ ២៥៥
អ៊ីម៉ែល : maff-sri@camintel.com
គេហទំព័រ : www.foodsecurity.gov.kh/sri